# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**អគ្គនាយកដ្ឋានឧស្សាហកម្ម**
នាយកដ្ឋានវាយតម្លៃទទួលស្គាល់
លេខ: ................ ន.វ.ស

## គោរពជូន
## ឯកឧត្តមអគ្គនាយកឧស្សាហកម្ម

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលការងារដែលនាយកដ្ឋានសម្រេចបានក្នុងរយៈពេល ១០ខែ នៃឆ្នាំ២០១៤ កន្លងមកទាក់ទងនឹងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជូនឯកឧត្តមអគ្គនាយក មេត្តាជ្រាបថា: តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងចូលរួមចំណែកអនុវត្តនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល សម្រាប់រយៈពេល ១០ ខែ នៃឆ្នាំ២០១៤ កន្លងទៅ នាយកដ្ឋានវាយតម្លៃទទួលស្គាល់បានខិតខំបំពេញការងារ និងសម្រេចបាននូវលទ្ធផលគួឲ្យលេចធ្លមួយចំនួន ដូចខាងក្រោម:

- បានរៀបចំប្រកាសស្តីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដោយធ្វើការកែសម្រួលជាបន្តបន្ទាប់រហូតដល់ការចុះហត្ថលេខាដាក់ឲ្យអនុវត្តជាផ្លូវការពីឯកឧត្តមទេសរដ្ឋមន្ត្រី នេះជាភារកិច្ច និងជាបទដ្ឋានគតិយុត្តិយ៉ាងសំខាន់ដែលនាយកដ្ឋានត្រូវអនុវត្ត
- បង្កើតត្រាមូលរបស់នាយកដ្ឋានចំនួន២ (ជាភាសាខ្មែរ និងអង់គ្លេស) និងត្រាសញ្ញាវាយតម្លៃទទួលស្គាល់សម្រាប់ប្រើប្រាស់ក្នុងការងារវាយតម្លៃទទួលស្គាល់ ដោយមានការឯកភាពពីក្រសួងមហាផ្ទៃ វាមានសារៈសំខាន់ណាស់ក្នុងការងារវាយតម្លៃទទួលស្គាល់
- ទៅចូលរួមក្នុងកិច្ចប្រជុំលើការងារវាយតម្លៃទទួលស្គាល់ នៅប្រទេសវៀតណាម ឡាវ ថៃ និងភូមា កិច្ចប្រជុំលើកទី២៦ ACCSQ/WG2 លើការងារវាយតម្លៃទទួលស្គាល់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ នៅទីក្រុង Bali ប្រទេសឥណ្ឌូនេស៊ី និងចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ISO/IEC 17065 ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ នៅប្រទេសសិង្ហបុរី ដោយបានទទួលនូវចំណេះដឹងថ្មីៗ និងការផ្លាស់ប្តូរនូវបទពិសោធន៍គ្នាទៅវិញទៅមកលើការងារវាយម្លៃទទួលស្គាល់

- រៀបចំបែបបទ និងនិតិវិធីក្នុងការចុះបញ្ជីជាអ្នកជំនាញវាយតម្លៃទទួលស្គាល់ដើម្បីអនុវត្ត ការងារវាយតម្លៃទទួលស្គាល់ស្របតាមគោលការណ៍អន្តរជាតិ នេះជាការងារចាំបាច់ ដែលធ្វើឲ្យដំណើរការវាយតម្លៃទទួលស្គាល់ប្រកបដោយគុណភាព និងប្រសិទ្ធភាព
- ដោយបានឯកភាពពីឯកឧត្តមទេសរដ្ឋមន្ត្រី នាយកដ្ឋានបានរៀបចំបែបបទ និងនិតិវិធី ដំណើការអនុវត្តការងារវាយតម្លៃទទួលស្គាល់ដោយឯករាជ្យ ស្របតាមស្តង់ដារអន្តរជាតិ ISO/IEC 17011
- សហការជាមួយស្ថាប័ន PTB នៃប្រទេសអាល្លឺម៉ង់ ដែលមានលោក Hanspeter Ischi ជាតំណាង និងជាអ្នកពិគ្រោះយោបល់ ដែលបានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជា ចំនួន៣លើក ដោយផ្តោតការពិភាក្សាលើការរៀបចំធ្វើពង្រាងច្បាប់ស្តីពីការវាយតម្លៃ ទទួលស្គាល់នៃកម្ពុជា ព្រមទាំងផ្តល់យោបល់លើការរៀបចំបែបបទ និងនិតិវិធីក្នុងការ អនុវត្តន៍ការងារវាយតម្លៃទទួលស្គាល់ និងរៀបចំនូវផែនការក្នុងការបណ្តុះបណ្តាលអ្នក ជំនាញវាយតម្លៃទទួលស្គាល់ និងមន្ត្រីនាយកដ្ឋាន ដើម្បីក្លាយជា Assessors ជាតិ និងអន្តរជាតិ
- រៀបចំប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ និងបានចុះហត្ថលេខាជាផ្លូវការពីឯកឧត្តមទេសរដ្ឋមន្ត្រី បង្កើតជាក្រុមប្រឹក្សាជាតិវាយតម្លៃ ទទួលស្គាល់ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តន៍ការងារវាយតម្លៃទទួល ស្គាល់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងភាពមិនលម្អៀង
- បានទទួលការស្នើសុំពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិសុំឲ្យនាយកដ្ឋានវាយតម្លៃទទួល ស្គាល់ ធ្វើការវាយតម្លៃទទួលស្គាល់លើផ្នែកចំនួន០៤ គឺ: ម៉ាស ទំហំ មាឌ និង សីតុណ្ហភាព ដោយការងារនេះនាយកដ្ឋានបានធ្វើការទំនាក់ទំនងជាមួយ BoA នៃ ប្រទេសវៀតណាមដើម្បីមកធ្វើការវាយតម្លៃទទួលស្គាល់ ដោយនាយកដ្ឋាននឹងបញ្ជូន មន្ត្រីក្នុងនាមជាអ្នកសង្កេតការណ៍ ដើម្បីបានសិក្សារៀនសូត្រពីដំណើរការការងារនេះ
- បានរៀបចំរួចរាល់បែបបទ និងនិតិវិធីក្នុងការចុះពិនិត្យមើលការផ្តល់មេដាយ ពានរង្វាន់ ផ្សេងៗ ដែលក្រុមហ៊ុន ឧស្សាហាកម្ម សិប្បកម្មទទួលបានមកពីក្នុង និងក្រៅប្រទេស តើការផ្តល់ជូនទាំងនោះពីស្ថាប័ន CABs ណាមួយ ហើយពិត ឬ មិនពិត ក្នុងគោលបំណង បង្កើនទំនុកចិត្តដល់អតិថិជន និងធានាបាននូវការប្រកួតប្រជែងដោយត្រឹមត្រូវ
- រៀបចំបែបបទ និងនិតិវិធីសម្រាប់ការងារចុះបញ្ជីវាយម្លៃទទួលស្គាល់ និងការងារវាយ តម្លៃទទួលស្គាល់ គំរូពាក្យស្នើសុំចុះបញ្ជីអ្នកជំនាញវាយតម្លៃទទួលស្គាល់ គំរូពាក្យស្នើ សុំចុះបញ្ជីវាយតម្លៃទទួលស្គាល់សម្រាប់មន្ទីរពិសោធន៍ គំរូពាក្យស្នើសុំចុះបញ្ជីនាំចេញ នាំចូលសម្ភារៈ បរិក្ខារមន្ទីរពិសោធន៍ គំរូវិញ្ញាបនបត្រ និងនិតិវិធីក្នុងការអនុវត្តការងារ ចុះបញ្ជីវាយតម្លៃទទួលស្គាល់ ក្នុងគោលបំណងសម្រួល និងគាំទ្រផលិតផល

ឧស្សាហកម្ម និងសិប្បកម្ម នាំចេញ នាំចូលទៅក្នុងទីផ្សារតំបន់ និងអន្តរជាតិ និងកាត់បន្ថយការចំណាយ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងការធ្វើពាណិជ្ជកម្មក្នុង និងក្រៅប្រទេស និងសុខុមាលភាពសង្គម

- បានធ្វើការទំនាក់ទំនង និងទទួលការឯកភាពពីអគ្គលេខាធិការរបស់ Thai Industrial Standards Institute ក្នុងការការចរចារ ដើម្បីឈានទៅចុះកិច្ចព្រមព្រៀងជាដៃគូរក្នុងការអនុវត្តការងារវាយតម្លៃទទួលស្គាល់ ការងារនោះមានសារៈសំខាន់ក្នុងការអនុវត្តការងារវាយតម្លៃទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ដែលនាយកដ្ឋានគ្រោងនឹងដំណើរការវាយតម្លៃទទួលស្គាល់ដល់គ្រប់អង្គភាព CABs ទាំងអស់ទូទាំងប្រទេសឲ្យទាន់ការមកដល់នៃ AEC ឆ្នាំ២០១៥ នេះ
- រៀបចំសុំចូលជាសមាជិកអង្គភាព PAC និង APLAC នាពេលឆាប់ៗនេះ
- ទៅជួបចរចារជាមួយ Thai Industrial Standards Institute ដើម្បីឈានទៅចុះកិច្ចព្រមព្រៀងយកធ្វើជាដៃគូរក្នុងការអនុវត្តការងារវាយតម្លៃទទួលស្គាល់ ជាលទ្ធផលបានជួបជាមួយតំណាង The National Standardization Council (NSC) និង តំណាង Office of the National Standardization Council (ONSC) ដោយបានឯកភាពគ្នាក្នុងការរៀបចំពង្រាង MoU ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងឧស្សហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សហកម្ម នៃព្រះរាជាណាចក្រថៃ ពង្រាង MoU នេះនឹងដាក់ឆ្លងស្នើសុំអនុសាសាសន៍ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមទេសរដ្ឋមន្ត្រី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គនាយកមេត្តាជ្រាប។

សូមឯកឧត្តមអគ្គនាយកមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី0៦ ខែតុលា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋាន**